ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពជាតិ
# ស្ដីពី
# ការអភិវឌ្ឍយុវជនកម្ពុជា
# ២០១៦-២០១៨

បានទទួលការឯកភាពពីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន
ក្នុងកិច្ចប្រជុំលើកទី១ នាថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦

## មាតិកា


១- សារបាន ........ ១

១.១- គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ........ ១

១.២- ស្ថានភាព ........ ១

១.៣- បញ្ហាអាទិភាព ........ ២

២- យុទ្ធសាស្ត្រ ........ ៣

២.១- ទស្សនវិស័យ ........ ៣

២.២- ក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍយុវជនកម្ពុជា ........ ៣

២.២.១- គោលការណ៍នៃការរៀបចំផែនការសកម្មភាពជាតិ ........ ៤

២.២.២- យន្តការអនុវត្តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ........ ៤

២.២.២.១- ក្រសួង ស្ថាប័នថ្នាក់ជាតិ ........ ៥

ក- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) ........ ៥

ខ- អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន (ក.ជ.យ.) ........ ៦

គ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ........ ៩

២.២.២.២- ស្ថាប័នថ្នាក់ក្រោមជាតិ ........ ១០

ក- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ........ ១០

ខ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ ........ ១០

គ- ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់ ........ ១១

២.២.២.៣- ដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល ........ ១១

៣- ផែនការសកម្មភាព ........ ១៣

ក- បរិយាយសង្ខេបអំពីវិសាលភាពផែនការសកម្មភាព ........ ១៣

៣.១- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី១ : អភិវឌ្ឍក្របខណ្ឌច្បាប់និងយន្តការ ........ ១៣

៣.១.១- សេវាកម្មព័ត៌មានយុវជនច្រកតែមួយ ........ ១៣

៣.១.២- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន ........ ១៤

៣.១.៣- ការគាំទ្រក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត ........ ១៤

៣.១.៤- ការសម្របសម្រួលជាមួយសង្គមស៊ីវិល ........ ១៥

៣.១.៥- ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ........ ១៦

៣.១.៦- ការតស៊ូមតិនៅក្នុងសភាជាតិ ក្រសួង ស្ថាប័ន និងថ្នាក់រាជធានី ខេត្ត ........ ១៦

៣.១.៧- ការស្រាវជ្រាវអំពីយុវជន ........ ១៧

៣.១.៨- ការពិនិត្យ កែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារយុវជន ........ ១៨

៣.១.៩- ការអភិវឌ្ឍធនធានមនុស្ស ........ ១៨

៣.១.១០- ការកៀរគរធនធាន ..................................................... ១៩

៣.២- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី២ : លើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាព ..................................................... ២០

៣.២.១- សាលារៀនជាទីកន្លែងមូលដ្ឋានសម្រាប់រៀនសូត្រតាមរយៈការអប់រំមានគុណភាព........២០

៣.២.២- យុវជនទទួលបាននូវគុណវុឌ្ឍិខ្ពស់..................................................... ២១

៣.២.៣- ឱកាសទទួលបានការអប់រំលើកទីពីរ..................................................... ២២

៣.២.៤- ការអភិវឌ្ឍលទ្ធភាពទទួលបានការសិក្សាបន្តឬការសិក្សាពេញមួយជីវិត..............២៣

៣.២.៥- ការគាំទ្រយុវជននៅពេលពួកគេកំពុងឈានចូលពេញវ័យ..................................២៤

៣.២.៦- សម្ភារៈនិងមធ្យោបាយបម្រើឱ្យយុវជនក្នុងសហគមន៍..........................................២៤

៣.២.៧- ការពង្រីកកម្មវិធីអប់រំក្រោយមធ្យមសិក្សានិងមជ្ឈមណ្ឌលយុវជនសម្រាប់ យុវជនក្រៅសាលា ជាពិសេស យុវជនពិការ ដើម្បីឱ្យពួកគេមានឱកាសបានចូលរួម យ៉ាងសកម្មក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ..................................................... ២៥

៣.២.៨- ប្រាក់កម្ចីសិក្សាសម្រាប់សិស្សនិងនិស្សិត..................................................... ២៦

៣.២.៩- ភាពជាតំណាងយុវជន..................................................... ២៧

៣.២.១០- ការលើកកម្ពស់បណ្តាញការងារនិងគំរូនៅក្នុងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា..........២៨

៣.២.១១- ព័ត៌មានវិទ្យានិងការអប់រំពីចម្ងាយ..................................................... ២៩

៣.៣- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៣ : បង្កើនការអប់រំ ការថែទាំ និងការផ្តល់សេវាសុខភាព..................................................... ២៩

៣.៣.១- ការប្រឹក្សាយោបល់ស្តីពីសុខភាពយុវជន..................................................... ២៩

៣.៣.២- ការយល់ដឹងរបស់យុវជនអំពីជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍........... ៣០

៣.៣.៣- ការគាំទ្រយុវតីមានគភ៌និងវត្តមានសិស្ស..................................................... ៣១

៣.៤- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៤ : បណ្តុះស្មារតីសហគ្រិនភាពនិងទីផ្សារការងារ.....៣២

៣.៤.១- ការប្រឹក្សាយោបល់ស្តីពីមុខរបរនៅតាមសាលារៀន..................................................... ៣២

៣.៤.២- សេវាកម្មប្រឹក្សាយោបល់ស្តីពីមុខរបរសម្រាប់យុវជន..................................................... ៣៣

៣.៤.៣- ការបង្កើតការងារសម្រាប់យុវជន..................................................... ៣៤

៣.៤.៤- ការគស្ម័មតិនិងភាពជាតំណាងយុវជននៅក្នុងស្ថាប័នរដ្ឋបាលនានា.......................៣៥

៣.៤.៥- ការអប់រំយុវសហគ្រិនភាព..................................................... ៣៥

៣.៤.៦- ការផ្តួចផ្តើមការអភិវឌ្ឍយុវសហគ្រាសជាតិ..................................................... ៣៦

៣.៥- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី៦ : បង្កើនការចូលរួមរបស់យុវជន..............................៣៧

៣.៥.១- ការពង្រឹងនិងពង្រីកក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជន..................................................... ៣៧

៣.៦- សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រទី១០ : បង្កើនការងារស្ម័គ្រចិត្ត ..................................៣៧

៣.៦.១- កម្មវិធីសេវាកម្មជាតិយុវជន..................................................... ៣៧

៣.៦.២- ការលើកកម្ពស់ការផ្តួចផ្តើមសហគមន៍..................................................... ៣៨

៣.៦.៣- ការសម្របសម្រួលនិងការអភិវឌ្ឍអន្តរភាពជាមួយការវិទ្ធិកម្ពុជា..................................៣៩

ខ- តារាងសង្ខេបសកម្មភាព ..................................................... ៤១

៤- កាលវិភាគរៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានគតិយុត្ត ..................................................... ៦១

៥- គម្រោងចំណាយ ..................................................... ៦១

៦- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ..................................................... ៦២

៦.១- ការពិនិត្យផលប៉ះពាល់ ..........៦២
៦.២- ការពិនិត្យតាមដានការអនុវត្តផែនការសកម្មភាពជាតិ ..........៦២
៦.៣- ការពិនិត្យតាមដានការអនុវត្តកម្មវិធីនិងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍយុវជនតាមវិស័យ ..........៦២
៦.៤- ការរៀបចំឯកសារឧបសម្ព័ន្ធផែនការសកម្មភាពជាតិ ..........៦៣
៧- សេចក្តីសន្និដ្ឋាន ..........៦៤

# បុព្វកថា



សូមស្វាគមន៍យុវជនកម្ពុជាទាំងអស់ !

ក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមក កម្ពុជាបានធ្វើឱ្យមានការប្រែប្រួលនិងអភិវឌ្ឍគួរឱ្យកត់សម្គាល់លើគ្រប់វិស័យ ជាពិសេស ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច។ ពីពេលនេះឆ្ពោះទៅសម្រេចចក្ខុ-វិស័យនៃការអភិវឌ្ឍប្រទេសឆ្នាំ២០៥០ កម្ពុជានឹងពឹងផ្អែកលើភាគលាភដែលខ្លួនមាន ជាពិសេស ការទាញយកសក្ដានុពលនៃប្រជាសាស្ត្រវ័យក្មេង ដែលស្ថិតក្នុងប្រភេទប្រជាជនសកម្មប្រមាណ៣០ភាគ-រយនៃប្រជាជនសរុប។ ដូចនេះ កម្ពុជាត្រូវធានាឱ្យបាននូវការផលិតធនធានមនុស្សដែលមានគុណភាព និងមានសមត្ថភាពអាចឈានចូលទៅក្នុងទីផ្សារការងារនិងប្រកបដោយភាពប្រកួតប្រជែង។

ការអភិវឌ្ឍយុវជនជាអាទិភាពបន្ទាន់និងជាការទទួលខុសត្រូវរបស់យើងទាំងអស់គ្នា រួមទាំងយុវជនខ្លួនឯងផ្ទាល់។ យុវជនមានកាតព្វកិច្ចចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើន និងស្មើមុខស្មើមាត់នៅលើឆាកអន្តរជាតិ រួមទាំងការអភិវឌ្ឍកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងភាពសុខដុម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្ដីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និងលើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម។ យុវជនជាអ្នកទទួលផលដោយផ្ទាល់ពីការអភិវឌ្ឍនិងជាកម្លាំងចលករជំរុញការលូតលាស់នៅកម្ពុជាផងដែរ ដូច្នេះការចូលរួមពីសំណាក់យុវជនក្នុងការដោះស្រាយបញ្ហាសង្គម ការបង្កើនការយល់ដឹងពីតម្លៃការងាររបស់យុវជន ការទទួលស្គាល់ពីសក្ដានុពល និងតួនាទីដ៏សំខាន់របស់យុវជន រួមទាំងការទទួលស្គាល់ពីបំណងប្រាថ្នា តម្រូវការ និងលក្ខខណ្ឌរបស់យុវជន គឺជាកត្តាគន្លឹះសម្រាប់កសាងប្រជាជាតិមួយដែលមានភាពរុងរឿងនិងពោរពេញដោយសន្តិភាព។

រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងយកចិត្តទុកដាក់លើការអប់រំ ការបណ្ដុះបណ្ដាល និងការអភិវឌ្ឍសមត្ថភាពយុវជនទាំងក្នុងនិងក្រៅសាលារៀន ការអប់រំ ថែទាំ និងការផ្ដល់ សេវា សុខភាពដល់យុវជន ការបណ្ដុះស្មារតីសហគ្រិនភាពនិងការបង្កើតទីផ្សារការងារ ការបង្កើនការចូលរួមរបស់យុវជន លើគ្រប់រូបភាពនិងការបង្កើនការងារស្ម័គ្រចិត្តរបស់យុវជន។

រាជរដ្ឋាភិបាលបានតាក់តែងគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា ដែលមានចក្ខុវិស័យ ប្រមូលផ្ដុំកម្លាំងគ្រប់មជ្ឈដ្ឋានក្នុងសង្គមជាតិ សំដៅរួមចំណែកអភិវឌ្ឍយុវជនឱ្យកាន់តែមានលក្ខណសម្បត្តិវិជ្ជមាននិងផ្ដល់ឱកាសឱ្យពួកគេអភិវឌ្ឍសក្ដានុពលក្នុងការអប់រំ ការងារ សុខភាព ការចូលរួមធ្វើសេចក្ដីសម្រេចចិត្ត និងការចូលរួមចំណែកអភិវឌ្ឍគ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។ ដើម្បីអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលបានរៀបចំក្របខណ្ឌច្បាប់និងយន្តការ អនុវត្តនៅគ្រប់កម្រិត ចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ ដែលគាំទ្រដោយផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា។

ការអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិស្ដីពីការអភិវឌ្ឍយុវជនកម្ពុជានឹងសម្រេចទៅបាន គឺអាស្រ័យលើការបន្តសមិទ្ធកម្មដែលមានកន្លងមក ការបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធ

ផលនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍យុវជន និងការបង្កើតឱកាសដល់យុវជន និងការអន្តរាគមន៍ថ្មីៗសម្រាប់អភិវឌ្ឍយុវជន ជាពិសេស ការកៀរគរកម្លាំងគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងថ្នាក់ ដឹកនាំនយោបាយ ស្ថាប័នជាតិ ដៃគូអភិវឌ្ឍ គ្រួសារ និងយុវជន។

ខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំងឡាយដែលបានខិតខំប្រឹងប្រែង រួមចំណែកតាមគ្រប់ទិដ្ឋភាព ដើម្បីជំរុញ ផ្សព្វផ្សាយ អនុវត្ត និងគាំទ្រគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជននិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាឱ្យបានជោគជ័យ។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជននិងតំណាងឱ្យរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំនឹងប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត កម្លាំងប្រាជ្ញាស្មារតី ដើម្បីរួមចំណែកអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជានិងផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា។ រាជរដ្ឋាភិបាលសង្ឃឹមនិងជឿជាក់ថា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល សហគមន៍ គ្រួសារ បុគ្គលនឹងលះបង់ធនធានសរុប មធ្យោបាយសរុប និងធ្វើជាកម្លាំងសរុបក្នុងការធានាអនុវត្តគោលនយោបាយជាតិនិងផែនការសកម្មភាពជាតិនេះឱ្យបានជោគជ័យដូចការរំពឹងទុក។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## ១. សារបាន

### ១.១. គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា

គោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ត្រូវបានទទួលការឯកភាពជាផ្លូវការពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១។ គោលនយោបាយនេះ ត្រូវបានរៀបចំឡើងក្រោមការដឹកនាំនិងសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងមាន កិច្ចសហការពេញលេញពីក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលនានា ដែលកំពុងបំពេញការងារពាក់ព័ន្ធនឹងយុវជន។ គោលនយោបាយជាតិបានកំណត់នូវយុទ្ធសាស្ត្រមួយចំនួនដើម្បីបំពេញការងារឱ្យស្របតាមវិស័យរបស់ខ្លួន។ ការអនុវត្តគោលនយោបាយជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជាអាចសម្រេចទៅបានប្រកបដោយប្រសិទ្ធភាព លុះត្រាតែគ្រប់វិស័យនៃសង្គមទទួលស្គាល់ពីសារៈសំខាន់នៃការអភិវឌ្ឍយុវជននិងតួនាទីយុវជនត្រូវបំពេញនៅក្នុងសង្គម។

ដើម្បីអនុវត្តគោលនយោបាយជាតិនេះ យន្តការមួយត្រូវបានបង្កើតឡើង **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន** ហៅកាត់ថា"**ក.ជ.យ.**" ដែលមានតួនាទីជាអ្នកសម្របសម្រួល តាមដាន វាយតម្លៃ និងជួយរាជរដ្ឋាភិបាលអំពីដំណើរការអភិវឌ្ឍយុវជនឱ្យមានប្រសិទ្ធភាព។ ការអនុវត្តការងាររបស់ **ក.ជ.យ.** នឹងស្ថិតក្រោមក្របខណ្ឌរបស់ផែនការសកម្មភាពជាតិស្តីពីការអភិវឌ្ឍយុវជនកម្ពុជា ២០១៦-២០១៨ ដែលជាមគ្គុទ្ទេសក៍សម្រាប់បង្ហាញផ្លូវដល់ប្រតិបត្តិការរបស់ខ្លួន ដោយផ្តោតលើយុវជន យេនឌ័រ សមាហរណកម្មការងារយុវជន បរិយាកាសនៃការផ្តល់សិទ្ធិអំណាច ការចូលរួមរបស់យុវជន ការឆ្លើយតប ប្រសិទ្ធផល ប្រសិទ្ធភាព តម្លាភាព លទ្ធភាព និងភាពចម្រុះ។ ផែនការសកម្មភាពជាតិនេះ មានគោលបំណងធានាឱ្យយុវជនមានអាយុចន្លោះពី១៥ឆ្នាំដល់៣០ឆ្នាំ មានការអភិវឌ្ឍកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាពនិងភាពសុខដុម ព្រមទាំងមានស្មារតីស្នេហាជាតិ ស្នេហាប្រជាជន ប្រកបដោយជំនឿជាក់លើខ្លួនឯង សេចក្តីថ្លៃថ្នូរ ភាពជាអ្នកដឹកនាំ និង លើកកម្ពស់ការយល់ដឹងទូលំទូលាយអំពីសង្គម។

### ១.២. ស្ថានភាព

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់លើយុវជន ដែលជាសសរទ្រូងប្រទេសជាតិ ដោយផ្តល់ការអប់រំ ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពយុវជនទាំងក្នុងនិងក្រៅសាលារៀន ការអប់រំ ថែទាំ និងការផ្តល់សេវាសុខភាពដល់យុវជន ការបណ្តុះស្មារតីសហគ្រិនភាពនិងការបង្កើតទីផ្សារការងារ ការបង្កើនការចូលរួមរបស់យុវជនលើគ្រប់រូបភាព និងការបង្កើនការងារស្ម័គ្រចិត្តរបស់យុវជន។ ទន្ទឹមនឹងនេះមានយុវជនមួយចំនួនពុំទាន់មានឱកាសពេញលេញក្នុងការទទួលបានការងារសមស្របនៅឡើយដោយផ្អែកលើកត្តានានា រួមមានយុវជនមានចំណេះដឹងតិចតួច(ទាំងចំណេះដឹងនិងបំណិនក្នុងការគិត) ធ្វើឱ្យពួកគេបានប្រឈមនឹងការលំបាកឬធ្លាក់ចូលក្នុងស្ថានភាពងាយរងគ្រោះដែលរួមមានការបោះបង់ការសិក្សា គុណភាពអប់រំនៅមានកម្រិត កង្វះជំនាញដែលសមស្របតាមតម្រូវការទីផ្សារធ្វើឱ្យពួកគេមានការបាត់បង់ជម្រើសរបស់ខ្លួន បញ្ហាកង្វះសុវត្ថិភាពក្នុងសង្គម ដូចជាការសេពគ្រឿងញៀន ការសេពគ្រឿងស្រវឹង គ្រោះថ្នាក់នៅតាមកន្លែងធ្វើការ និងចំណាកស្រុក។ ហេតុផលទាំងនេះហើយដែលជាហេតុធ្វើឱ្យយុវជនទទួលបានទទួលប្រាក់កម្រៃទាប ក្នុងនោះស្ត្រីមិនសូវទទួលបានការងារធ្វើដោយកម្រៃខ្ពស់នៅឡើយ។

នៅក្នុងអត្ថបទ Matching Aspirations: Skills for Implementing Cambodia's Growth Strategy នាឆ្នាំ២០១២ និយោជកចំនួន ៧៣% បានបញ្ជាក់ថាអ្នកបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យពុំមានជំនាញសមស្របតាមតម្រូវការ ៦២% បានបញ្ជាក់ថាអ្នកដែលបានបញ្ចប់ការសិក្សាពីមជ្ឈមណ្ឌល បណ្តុះបណ្តាលវិជ្ជាជីវៈពុំទាន់មានជំនាញច្បាស់លាស់

៣១% បានបញ្ជាក់ថាមានការលំបាកក្នុងការបណ្តុះបណ្តាលឬការបង្កើនជំនាញរបស់ខ្លួន ៧០% បានបញ្ជាក់ថាមានកង្វះខាតលើជំនាញគ្រប់គ្រាន់សម្រាប់ការងារគ្រប់គ្រង ៣៦%បានបញ្ជាក់ថាខ្វះជំនាញគ្រប់គ្រងកម្រិតកណ្តាលនិងការត្រួតពិនិត្យ និង៣៩%បានបញ្ជាក់ថាខ្វះជំនាញវិជ្ជាជីវៈ។ កម្ពុជាកំពុងជួបប្រទះនឹងបញ្ហាប្រឈមកង្វះខាតជំនាញទន់(ជំនាញក្នុងការសម្រេចចិត្តនិងវិភាគ) និងជំនាញបច្ចេកទេស។ វិនិយោគិនមិនអាចរកកម្មករជំនាញបានគ្រប់គ្រាន់ នៅខណៈដែលនិស្សិតបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យមិនអាចរកការងារធ្វើបាន ដោយសារតែការសិក្សាមុខជំនាញមិនស្របតាមតម្រូវការទីផ្សារការងារ។ កម្ពុជាមានកម្លាំងពលកម្មដែលមានជំនាញទាប ជាហេតុធ្វើឱ្យប្រាក់បៀវត្សមានកម្រិតទាប។

ចំណែកឯវិស័យអប់រំនៅកម្រិតមធ្យមសិក្សាក្នុងរយៈពេលមួយទសវត្សកន្លងទៅនេះ ការចូលរៀននៅបឋមសិក្សាមានការកើនឡើងយ៉ាងខ្លាំង នាំឱ្យមានសម្ពាធយ៉ាងធ្ងន់ធ្ងរទៅលើការចូលរៀននៅកម្រិតមធ្យមសិក្សា។ អត្រាពិតនៃការសិក្សានៅបឋមសិក្សាសម្រេចបាន៩៧%នៅក្នុងឆ្នាំសិក្សា២០១២-២០១៣។ ដោយឡែក អត្រាពិតនៃការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ មានត្រឹមតែ ៣៨% ប៉ុណ្ណោះ ដែលក្នុងនោះ ៥០%ជាសិស្សស្រី ចំណែកឯអត្រាពិតនៃការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិសម្រេចបាន១៨%។ បញ្ហាប្រឈមនៃវិស័យអប់រំនៅកម្ពុជាគឺ អត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ ជាពិសេសនៅមធ្យមសិក្សាបឋមភូមិ។ អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាស្មើនឹង៨០% តែមានសិស្សប្រមាណ២០%បានបោះបង់ការសិក្សាមុននឹងបញ្ចប់ថ្នាក់ទី៩។ កត្តាសំខាន់ដែលធ្វើឱ្យសិស្សបោះបង់ការសិក្សាច្រើនគឺ ការចំណាយក្នុងការធ្វើដំណើរទៅសាលា ការធ្វើការផ្ទះ និងកាលានុវត្តភាពការងារដែលនឹងបាត់បង់ប្រសិនបើបន្តរៀនទៀត។ អ្នកសិក្សាក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួនត្រឹម៦%ប៉ុណ្ណោះ។

គម្លាតនៃការទទួលបានសេវាអប់រំ គុណភាពអប់រំនៅទាប និងសមត្ថភាពស្ថាប័ននៅមានកម្រិតបង្កជាឧបសគ្គក្នុងការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍប្រកបដោយបរិយាបន្ន បានធ្វើឱ្យកម្ពុជាមិនអាចទាញយកផលប្រយោជន៍បានជាអតិបរមាពីសហគមន៍សេដ្ឋកិច្ចអាស៊ាន។ វិទ្យាល័យភាគច្រើនខ្វះខាតគ្រូមានបទពិសោធ សម្ភារៈសិក្សា ឧបករណ៍បង្រៀន សៀវភៅអាន បន្ទប់ពិសោធវិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ និងបណ្ណាល័យជាដើម។

### ១.៣- បញ្ហាអាទិភាព

ដើម្បីបង្កើតការងារសម្រាប់យុវជនប្រមាណជា៣៦៦.០០០នាក់ ដែលចូលទៅក្នុងទីផ្សារការងាររៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបាននិងកំពុងជំរុញឱ្យសាកលវិទ្យាល័យនិងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើការកែលម្អកម្មវិធីសិក្សាដើម្បីផ្សារភ្ជាប់ការអប់រំជាមួយការងារ ធ្វើការអភិវឌ្ឍជំនាញចាំបាច់

预览已结束，完整报告链接和二维码如下：

https://www.yunbaogao.cn/report/index/report?reportId=5_19507